# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❖❖⚖❖❖

ក្រសួងយុត្តិធម៌

លេខ : ២២១ កយ.ប្រក/១៥

# ប្រកាស

## ស្តីពី

## ការផ្តល់នីតិសម្បទាដល់មន្ត្រីស៊ើបអង្កេតអន្តរជាតិថ្មី នៃការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

---

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតអោយមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- បានឃើញវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧
- បានឃើញវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានវិសោធនកម្ម ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៨
- យោងលិខិតលេខ ១០៤៦២ អ.វ.ត.ក/វ.ប ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សម្រេច

**ប្រការ ១** ៖ ត្រូវបានផ្តល់នីតិសម្បទាដល់មន្ត្រីស៊ើបអង្កេតអន្តរជាតិថ្មីចំនួន ១ រូប នៃការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានអត្តសញ្ញាណដូចខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំ កំណើត | សញ្ជាតិ | ថ្ងៃខែឆ្នាំ ចូលធ្វើការ |
|---|---|---|---|---|---|
| ១ | **Stephen Owen Tedder** | ប្រុស | ២៨-០២-១៩៦១ | អូស្ត្រាលី | ០៥-០៧-២០១៥ |

<u>**ប្រការ ២**</u> ៖ ការផ្តល់នីតិសម្បទាដល់មន្ត្រីស៊ើបអង្កេតអន្តរជាតិថ្មីនេះ នឹងអស់សុពលភាពក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

- នៅពេលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចប់បេសកកម្មរបស់ខ្លួន
- ឬសាមីខ្លួនពុំបានអនុវត្តតាមល័ក្ខខ័ណ្ឌ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- ឬសាមីខ្លួនបញ្ចប់ភារកិច្ចរបស់ខ្លួន ក្នុងមុខងារបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

<u>**ប្រការ ៣**</u> ៖ សាមីខ្លួន ដែលមានឈ្មោះដូចក្នុងប្រការ ១ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**អង្គ វង្ស វឌ្ឍនា**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៣

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ